**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០៧/ ០២៤ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជម្រះក្តី
- បានឃើញព្រះរាជក្រមលេខ ០៩/ នស/ ៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៤/ ២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលនិរាករណ៍ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៣៩៩/ ៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៦០២/ ១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៣០៩/ ៣៤៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/ រកត/ ០៦០២/ ១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញសេចក្តីសម្រេចលេខ ០៣ សសរ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមសំណើរបស់សហប្រធាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**

អនុក្រឹត្យនេះមានគោលដៅកំណត់ អំពីយន្តការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អំពីតួនាទី ភារកិច្ច និងសមាសភាព ព្រមទាំងដំណើរការនៃយន្តការនេះ ក្នុងគោលបំណងជួយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការបំពេញតួនាទី

របស់ខ្លួនជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចរំលឹក ដាស់តឿន កែលំអ ឬចាត់ការ តាមនីតិវិធីស៊ើបអង្កេត ស្រាវជ្រាវ និងដាក់ឬមិនដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ជំពូកទី២

## យន្តការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ

## នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

**មាត្រា២.**

ត្រូវបានបង្កើតយន្តការមួយដើម្បីបង្កើនប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានឈ្មោះថា «អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម» ហៅកាត់ថា (អ.ក.វ) ស្ថិតក្រោមការដឹកនាំ និងបញ្ជាផ្ទាល់ពីប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដែលជាប្រធានក្រុមប្រឹក្សាវិន័យ អាស្រ័យទៅតាមករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា។

## ជំពូកទី៣

## តួនាទី ភារកិច្ច និងសមាសភាព

## របស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ)

**មាត្រា៣.**

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ទទួលពាក្យបណ្តឹង និងតាមដានព័ត៌មានទាំងឡាយពាក់ព័ន្ធទៅនឹងចៅក្រម ព្រះរាជអាជ្ញា និងរាយការណ៍ជូនប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- រំលឹក ដាស់តឿនចៅក្រម ព្រះរាជអាជ្ញា ឱ្យអនុវត្តក្រមសីលធម៌ចៅក្រមឱ្យបានត្រឹមត្រូវ
- ចុះធ្វើអធិការកិច្ចជាប្រចាំស្វែងយល់អំពីការលំបាក ការងាយស្រួល ចំណុចខ្វះខាត ចំណុចល្អ ដែលកំពុងកើតមានច្រើននៅតាមតុលាការនានា ណែនាំរបៀបរបបការងារ និងធ្វើ

របាយការណ៍លើកសំណើរវិធានការជូនប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចាត់ការជាបន្ត

- ចុះស៊ើបអង្កេតករណីមិនប្រក្រតីតាមបណ្តាសាលាជម្រះក្តីនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមពាក្យបណ្តឹង
- ធ្វើរបាយការណ៍ជូនប្រធានក្រុមប្រឹក្សាវិន័យ ដោយលើកនូវអង្គហេតុ អង្គច្បាប់ និងធាតុចេតនា របស់ចៅក្រម ឬព្រះរាជអាជ្ញា ស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងការសម្រេចរបស់ចៅក្រម ព្រះរាជអាជ្ញានោះ និងលើកមតិដោះស្រាយ
- ចាត់ការឱ្យថតចម្លងឯកសារដែលពាក់ព័ន្ធនឹងចៅក្រម ឬព្រះរាជអាជ្ញា ដែលត្រូវគេប្តឹងជូនសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ធ្វើទំនាក់ទំនងផ្នែករដ្ឋបាលជាមួយក្រសួងយុត្តិធម៌ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត
- រៀបចំរាល់កិច្ចប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើកំណត់ហេតុអង្គប្រជុំ គ្រប់គ្រងឯកសារ និងពាក្យបណ្តឹងនានា
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រគល់ឱ្យ។

**មាត្រា៤.**

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ឌិត មុន្ទី** | សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | ជា ប្រធាន |
| ២-ឯកឧត្តម **ប៉ាល់ ចន្ទតារា** | តំណាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | ជា អនុប្រធាន |
| ៣-លោក **សេង ប៊ុនឃាង** | ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | ជា អនុប្រធាន |
| ៤-ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជា សមាជិក |
| ៥-លោក **ជ័យ សុផល** | ចៅក្រមតុលាការកំពូល | ជា សមាជិក |
| ៦-លោក **ច័ន្ទ ទេរី** | ចៅក្រមតុលាការកំពូល | ជា សមាជិក |

| | | |
|---|---|---|
| ៧-លោក **ប៉ុល សំអឿន** | ចៅក្រមសាលាឧទ្ធរណ៍ | ជា សមាជិក |
| ៨-លោក **ម្លូច់ សំណាង** | ចៅក្រមសាលាឧទ្ធរណ៍ | ជា សមាជិក |
| ៩-លោក **ហ៊ាន រិទ្ធ** | ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ជា សមាជិក |
| ១០-លោក **អឿង សៀង** | អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិក |
| ១១-លោក **សេង នាង** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិក |
| ១២-លោក **ឌុច គឹមសន** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិក |
| ១៣-លោក **យូ ម៉ិនណា** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិក |
| ១៤-លោកស្រី **ចាំង ស៊ីណាត** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិកា |
| ១៥-លោក **ហ្វួត វុទ្ធី** | ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម | ជា សមាជិក |
| ១៦-លោក **កើត វណ្ណារ៉េត** | ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រៃវែង | ជា សមាជិក |
| ១៧-លោក **សុខ រឿន** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិក |
| ១៨-លោក **មាស ច័ន្ទពិសិដ្ឋ** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | ជា សមាជិក |
| ១៩-អ្នកស្រី **អ៊ូ រមនា** | ក្រឡាបញ្ជីមហាអយ្យការអមតុលាការកំពូល | ជា លេខាធិការ |
| ២០-កញ្ញា **ហេង ម៉ូនា** | នាយកក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ | ជា លេខាធិការ |
| ២១-លោក **អ៊ុំ ម៉ន** | ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ | ជា ជំនួយការ |
| ២២-លោក **ហេង ធីរៈ** | ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ | ជា ជំនួយការ |

ក្នុងការបំពេញបេសកកម្មរបស់ខ្លួន អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) ប្រើប្រាស់នូវមន្ត្រីដូចខាងក្រោម ជាជំនួយការៈ

១-មន្ត្រីនៃក្រុមការងាររបស់ក្រសួងយុត្តិធម៌ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហៅកាត់ថា «ក្រុមការងារ ក.យ.ឧ.ក្រ.ច» សម្រាប់ជំនួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

២-ចៅក្រម ឬព្រះរាជអាជ្ញាផ្សេងទៀតតាមការចាំបាច់ក្រោយពីបានការយល់ព្រមពីប្រធានក្រុមប្រឹក្សាវិន័យលើសំណើរបស់ប្រធានអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ)។

ក្រៅពីនេះ អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) អាចសុំកិច្ចសហការពីមន្ត្រីនគរបាល ដែលជានគរបាលជាតិ កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ចនៃក្រសួងស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៤

## ដំណើរការនៃអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ

**មាត្រា៥.**

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានទីតាំងនៅអាគារឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ អង្គភាពនេះបើកការប្រជុំរបស់ខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិកោះអញ្ជើញ។

ប្រធានអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានសិទ្ធិអញ្ជើញ ចៅក្រម ព្រះរាជអាជ្ញា ភាគី សាក្សី ឬមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំទាក់ទងនឹងពាក្យបណ្តឹង។

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) ចុះធ្វើអធិការកិច្ចមួយដងក្នុង១ខែយ៉ាងតិច។

**មាត្រា៦.**

ក្រុមប្រឹក្សាវិន័យនៃឧត្តមប្រឹក្សានៃអង្គចៅក្រម ត្រូវដោះស្រាយរាល់ពាក្យបណ្តឹងឱ្យទាន់ពេលវេលាប្រកបដោយយុត្តិធម៌ និងតម្លាភាព។

នីតិវិធីនៃការទទួល និងដោះស្រាយពាក្យបណ្តឹងត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ)។

**មាត្រា៧.**

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានសិទ្ធិប្រើប្រាស់ត្រារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការបំពេញភារកិច្ច។

**មាត្រា៨.**

ថវិកាសម្រាប់ដំណើរការការងាររបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ(អ.ក.វ) ត្រូវប្រើប្រាស់ថវិកាសម្រាប់ដំណើរការការងាររបស់ក្រុមជំនួយការក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែងក្នុងស.ជ.ណ លេខ០៩ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១។

## ជំពូកទី៥

## អវសានបញ្ញត្តិ

**មាត្រា៩.**

អនុក្រឹត្យលេខ ១៦០ អនក្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា៩ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**សុខ អាន** — ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ឌិត មុន្ទី** — ប្រធានតុលាការកំពូល

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការកំពូល
-សាលាឧទ្ធរណ៍
-សាលាដំបូងរាជធានី-ខេត្ត
-ដូចមាត្រា១០
-រាជកិច្ច